**Declassified to Public**
**28 November 2018**

លេខ: D184/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 24 / 08 / 2016
ម៉ោង (Time/Heure) : 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦

ភាសា ៖ ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉េន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES
ជេត វណ្ណលី
ឡោ ជុនធី
Yiqiang LIU
ស៊ិន ស៊ីវ៉ន
Beini YE

# I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ នៅក្នុងសំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ("សំណើសុំមតិយោបល់")[1] ខ្ញុំបានជូនដំណឹងភាគីទាំងអស់ អំពីគោលបំណងរបស់ខ្ញុំដែលមិនចង់ស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោម[2]ដែលបានចោទនៅក្នុងដីកាសន្និដ្ឋាន។

- **អង្គហេតុទី ១**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២២[3]។
- **អង្គហេតុទី ២**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[4]។
- **អង្គហេតុទី ៣**- ការចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅប្រទេសវៀតណាម ក្រៅពីកោះនានា ដែល កម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជារបស់ខ្លួន និងតំបន់ព្រំដែនភាគខាងកើត[5]។
- **អង្គហេតុទី ៤**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹង គុកលេខ ៨១០[6]។
- **អង្គហេតុទី ៥**-ការចោទប្រកាន់នានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខផ្សេងទៀតដែលមិនបានកំណត់អត្តសញ្ញាណ គ្រប់គ្រងដោយកងទ័ពបដិវត្តន៍កម្ពុជា("ក.ប.ក")[7]។
- **អង្គហេតុទី ៦**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្ស ស្ទឹងតូច[8]។

---

[1]សំណុំរឿង ០០៣ ឯកសារ D184 *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ("សំណើសុំមតិយោបល់")។

[2]សូមកត់សម្គាល់ថា ការចោទប្រកាន់នានាគឺសំដៅលើអង្គហេតុមួយ។

[3]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៦។

[4]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៧។

[5]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥ និង ៦២។

[6]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៣ និង ៦៤។ *សូមមើលផងដែរ* សំណុំរឿង ០០៣ ឯកសារ D105/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D105 ទាក់ទងនឹងមន្ទីរសន្តិសុខ ៨០៨, ៨០៩ និង ៨១០* ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៤។

[7]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៥។

[8]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៦។

- **អង្គហេតុទី ៧**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការចូលរួមរបស់ ក.ប.ក នៅក្នុង "ការបោសសម្អាត"ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា ដោយមិនរាប់បញ្ចូលការចោទប្រកាន់អំពីការបោសសម្អាតសមាជិកនៅកង/អង្គភាព របស់ ក.ប.ក ដែលមានទីតាំងនៅតំបន់ទាំងនោះទេ[9]។

២. ខ្ញុំបានកត់សម្គាល់ថា អង្គហេតុទី ១ ដល់ទី ៥ និងអង្គហេតុទី ៧ ជាបឋម ហាក់ស្តែងឱ្យឃើញថាត្រូវលើកលែងការចោទប្រកាន់មួយចំនួន ចំណែកឯ អង្គហេតុទី ១, ២ និង ៦ អាចសាកសមសម្រាប់ការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន*[10]។ ខ្ញុំបានស្នើឱ្យភាគីទាំងអស់ ត្រូវដាក់សារណា/សេចក្តីសន្និដ្ឋានថាតើខ្លួនពិចារណាលើកលែងការចោទប្រកាន់ដែរឬអត់យោងតាមវិធានផ្ទៃក្នុង ៦៧(៣) ឬថាតើខ្លួនយល់ឃើញថា ការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ទាក់ទងនឹងអង្គហេតុទី ១ ដល់ទី ៧ គឺជាត្រឹមត្រូវដែរឬអត់[11]។

៣. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តី មាស មុត ("មេធាវីការពារក្តី") បានឆ្លើយតបថា ខ្លួន"យល់ឃើញថា វិធានផ្ទៃក្នុង ៦៦*ស្ទួន* មានភាពច្បាស់លាស់" ហើយបានស្នើសុំការអនុញ្ញាតឱ្យឆ្លើយតបថែមទៀតទៅនឹងសេចក្តីសន្និដ្ឋានណាមួយពីសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី[12]។

៤. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួន ដោយបញ្ជាក់ថាមិនទាន់ដល់ពេលដែលត្រូវសម្រេចជាស្ថាពរថាតើការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ឬ ៦៧ គឺជាត្រឹមត្រូវបំផុតឬអត់នោះទេ ប៉ុន្តែ អាស្រ័យតាមការពិចារណាមួយចំនួន ស.ព.អ គាំទ្រថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនគួរស៊ើបអង្កេតថែមទៀតលើអង្គហេតុទី ១ ដល់ទី ៧

---

[9]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦៦។

[10]សំណើសុំមតិយោបល់ កថាខណ្ឌ ៥។

[11]សំណើសុំមតិយោបល់ កថាខណ្ឌ ៨។

[12]សំណុំរឿង ០០៣ ឯកសារ D184/1 *លិខិតរបស់ មាស មុត ឆ្លើយតបទៅនឹងសំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀត ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦* ទំព័រ ៥ ("លិខិតរបស់មេធាវីការពារក្តី")។

ឡើយ[13]។ គាត់បានបន្ថែមថា អង្គហេតុទី ៧ នឹងងាយអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ជាង លើកលែងការចោទប្រកាន់មួយចំនួន ដោយផ្តល់មតិយោបល់ថា ការស៊ើបអង្កេតទាំងនោះគួរ បន្តតែចំណុចណាដែលពាក់ព័ន្ធនឹងធាតុផ្សំយុត្តាធិការ ធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ និងអង្គហេតុផ្សេងទៀតដែលស្ថិតនៅក្រោមការស៊ើបអង្កេតតែប៉ុណ្ណោះ[14]។ ស.ព.អ ក៏បាន បញ្ជាក់ថែមទៀតថា គាត់នឹងមិនជំទាស់ប្រឆាំងនឹងការផ្អាកការស៊ើបអង្កេតលើ"ការបោស សម្អាត"កងពល ៥០២ និង ៣១០ ដែលបានលើកឡើងនៅកថាខណ្ឌ ៤៤-៥១ នៃដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ (**អង្គហេតុទី ៨**) ហើយអង្គហេតុទាំងនេះអាចដកចេញបានដោយ ប្រើប្រាស់វិធានផ្ទៃក្នុង ៦៦*ស្ទួន*[15]។

៥. មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនបានឆ្លើយតបទៅនឹងសំណើសុំមតិយោបល់ឡើយ ហើយ មេធាវីការពារក្តី មិនបានដាក់ការឆ្លើយតបថែមទៀតទៅនឹងចម្លើយតបរបស់ ស.ព.អ ដែរ។

## II. ពិភាក្សា

### i. <u>វិធានផ្ទៃក្នុង ៦៦*ស្ទួន* និង ៦៧</u>

៦. ពេលវេលាសម្រាប់សម្រេចលើការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ឬការលើកលែងការចោទ ប្រកាន់យោងតាមវិធានផ្ទៃក្នុង ៦៧ គឺនៅពេលបញ្ចប់កិច្ចស៊ើបសួរ។

៧. មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*(២) ខ្ញុំត្រូវជូន ដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយទៅភាគីទាំងអស់ បន្ទាប់មក ភាគី នឹងមានពេល ១៥ ថ្ងៃដើម្បីដាក់សារណា។ ដូចគ្នានេះដែរ ក្នុងករណីដែលខ្ញុំយល់ឃើញថា កិច្ច ស៊ើបសួរ បានបញ្ចប់ហើយ ខ្ញុំត្រូវជូនដំណឹងភាគីទាំងអស់យោងតាមវិធានផ្ទៃក្នុង ៦៦(១)។ ការជូនដំណឹងនេះនាំឱ្យមានការកំណត់កាលបរិច្ឆេទជាបន្តបន្ទាប់សម្រាប់ដាក់សំណើសុំ

---

[13]សំណុំរឿង ០០៣ ឯកសារ D184/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិសុំយោបល់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលមិនត្រូវស៊ើបអង្កេតបន្ថែម* ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ ("ចម្លើយតប") កថាខណ្ឌ ៣, និង ១៥-២១។

[14]ចម្លើយតប កថាខណ្ឌ ១៩។

[15]ចម្លើយតប កថាខណ្ឌ ២២-២៣។

បំពេញកិច្ចស៊ើបសួរ ដីកាបង្គាប់ និងបណ្តឹងឧទ្ធរណ៍ដែលអាចមាន ព្រមទាំងដីកាសន្និដ្ឋានស្ថាពរពី ក.ស.ព យោងតាមវិធានផ្ទៃក្នុង ៦៦។

៨. ខ្ញុំកត់សម្គាល់លើទឡ្ហីករណ៍របស់ ស.ព.អ ទាក់ទងនឹងលទ្ធភាពអាចប្រើប្រាស់វិធានផ្ទៃក្នុង ៦៦*ស្ទួន* ក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់[16] ហើយខ្ញុំនឹងពិចារណាលើទឡ្ហីករណ៍ទាំងនោះឱ្យបានត្រឹមត្រូវក្នុងពេលវេលាសមស្រប។

៩. ជាចុងក្រោយ ខ្ញុំយល់ឃើញថា វិធានផ្ទៃក្នុង ៦៦*ស្ទួន* (៥) បញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលដកចេញអង្គហេតុ ភស្តុតាងទាក់ទងនឹងអង្គហេតុទាំងនេះនៅតែអាចពឹងផ្អែកបានចំពោះចំណុចណាដែលពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។ តាមការយល់ឃើញរបស់ខ្ញុំ វិធីនេះក្នុងករណីដែលមានកាលៈទេសៈប្រែប្រួលចាំបាច់ គឺត្រូវអនុវត្តចំពោះភស្តុតាងជាគ្រឹះនៃអង្គហេតុដែលអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួន យោងតាមវិធានផ្ទៃក្នុង ៦៧។

១០. សម្រាប់សេចក្តីជូនដំណឹងនេះ បន្ទាប់ពីបានពិចារណាលើទឡ្ហីករណ៍របស់ ស.ព.អ ខ្ញុំបង្ហាញពីមូលហេតុនៃគោលបំណងបច្ចុប្បន្នរបស់ខ្ញុំទាក់ទងនឹងអង្គហេតុទី ១ ដល់ទី ៨ ជាជាងជូនដំណឹងជាផ្លូវការអំពីការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* (២) ឬក៏បញ្ចប់កិច្ចស៊ើបសួរលើអង្គហេតុណាមួយយោងតាមវិធានផ្ទៃក្នុង ៦៦។

១១. បច្ចុប្បន្ននេះ អង្គហេតុទី ១, ២, ៦ និង ៧ ជាបឋម ហាក់ស្តែងឱ្យឃើញថាអាចត្រូវអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ហើយស្ថិតនៅក្នុងប្រភេទអង្គហេតុដែលកិច្ចស៊ើបសួរនឹងមិនត្រូវបន្ត (អង្គហេតុប្រភេទ ក)។ អង្គហេតុទី ៣ ដល់ ៥ ជាបឋម ហាក់ស្តែងឱ្យឃើញថាអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួនយោងតាមវិធានផ្ទៃក្នុង ៦៧ ហើយស្ថិតនៅក្នុងប្រភេទអង្គហេតុដែលកិច្ចស៊ើបសួរនឹងមិនត្រូវបន្ត(អង្គហេតុប្រភេទ ខ)។ កិច្ចស៊ើបសួរលើអង្គហេតុទី ៨ នឹងត្រូវបន្ត (អង្គហេតុប្រភេទ គ)។

១២. ក្នុងករណីដែលបានផ្អាកហើយ កិច្ចស៊ើបសួរក៏អាចបើកស៊ើបសួរឡើងវិញបានដែរប្រសិនបើកាលៈទេសៈតម្រូវឱ្យធ្វើដូច្នេះ ហើយក្នុងករណីបែបនេះ ភាគីទាំងអស់នឹងត្រូវផ្តល់ជូននូវ

---

[16]ចម្លើយតប កថាខណ្ឌ ១៦ និង ១៩។

ពេលវេលាគ្រប់គ្រាន់ដើម្បីសម្របសម្រួលការងាររបស់ខ្លួនជាមួយនឹងកាលៈទេសៈដែលបានប្រែប្រួលបែបនេះ។

១៣. ខ្ញុំបានប្រកាន់យកវិធីផ្អាកបណ្តោះអាសន្ននេះ ដែលមិនមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងនោះទេ គឺដើម្បីផ្តល់ជូនភាគីទាំងអស់ ឱ្យទទួលបានការធានា និងភាពច្បាស់លាស់ជាអតិបរមាអំពីបញ្ហានានាដែលភាគីទាំងអស់ និងខ្ញុំ នឹងចាំបាច់ត្រូវចាត់ចែងធនធានមានកំណត់របស់យើង និងដើម្បីឱ្យកិច្ចស៊ើបសួរដំណើរការទៅប្រកបដោយប្រសិទ្ធភាពឱ្យបានមុនពេលកាលបរិច្ឆេទកំណត់ជាផ្លូវការតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* និងការបញ្ចប់កិច្ចស៊ើបសួរ។

ii. អង្គហេតុប្រភេទ ក៖ អង្គហេតុទី ១,២, ៦ និង ៧

១៤. ស.ព.អ គាំទ្រឱ្យផ្អាកកិច្ចស៊ើបសួរលើអង្គហេតុទី ១,២ និង ៦ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*[17]។ ស.ព.អ ក៏គាំទ្រឱ្យផ្អាកកិច្ចស៊ើបសួរលើអង្គហេតុទី ៧ ផងដែរ ដូចបានបង្ហាញនៅក្នុងសំណើសុំមតិយោបល់ ថាជាការត្រឹមត្រូវសម្រាប់លើកលែងការចោទប្រកាន់មួយចំនួន ប៉ុន្តែ ដោយសារពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់ ទើប ស.ព.អ លើកឡើងថា អង្គហេតុនេះអាចងាយអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ជាងការលើកលែងការចោទប្រកាន់[18]។

១៥. ចំពោះអង្គហេតុទី ៧ ស.ព.អ បន្ថែមថា កិច្ចស៊ើបសួរទាំងនោះគួរបន្តអនុវត្តដោយមានកម្រិត និងតែត្រង់ចំណុចណាដែលពាក់ព័ន្ធនឹងធាតុផ្សំយុត្តាធិការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ និងភាពពាក់ព័ន្ធជាមួយនឹងអង្គហេតុផ្សេងទៀតដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ ជាពិសេស "ការបោសសម្អាត"កងពល ១៦៤ និង ១១៧[19]។

១៦. ខ្ញុំបញ្ជាក់បំភ្លឺថា ក្រោយត្រួតពិនិត្យឡើងវិញ មើលឃើញថា ការយល់ឃើញរបស់ ស.ព.អ អំពីអង្គហេតុទី ៧ គឺស្របគ្នានឹងការយល់ឃើញរបស់ខ្ញុំអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុទាំង ៤ ដែលស្ថិតនៅក្នុងអង្គហេតុប្រភេទ ក។

---

[17]ចម្លើយតប កថាខណ្ឌ ១៥-១៦។

[18]ចម្លើយតប កថាខណ្ឌ ១៩-២០។

[19]ដូចជើងទំព័រខាងលើ។

iii. **អង្គហេតុប្រភេទ ខ៖ អង្គហេតុទី ៣ ដល់ ៥**

១៧. ចំពោះអង្គហេតុទី ៣ ស.ព.អ បញ្ជាក់ថា ការលើកយោងលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត នៅក្នុង"ប្រទេសវៀតណាម" និងនៅក្នុងអំឡុងពេល "វាយប្រហារទៅក្នុងប្រទេសវៀតណាម "ត្រូវកម្រិតការយល់ឃើញថានៅត្រឹម "ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅលើកោះនានាដែល ទាមទារដោយកម្ពុជាប្រជាធិបតេយ្យ និងនៅលើទឹកដីប្រទេសកម្ពុជា និងប្រទេសវៀតណាម តាមតំបន់ព្រំប្រទល់រវាងប្រទេសទាំងពីរ"[20]។ កិច្ចស៊ើបសួរនឹងកម្រិតវិសាលភាពតាមនេះ។

១៨. ចំពោះអង្គហេតុទី ៤ ស.ព.អ មិនប្រមើលឃើញថាមានការជំទាស់ណាមួយប្រឆាំងនឹងការ លើកលែងការចោទប្រកាន់មួយចំនួនឡើយ ក្នុងករណីដែលកិច្ចខិតខំប្រឹងប្រែងស៊ើបសួរទាំង អស់បានប្រើប្រាស់អស់លទ្ធភាព ហើយ ស.ព.អ ស្នើសុំឱ្យប្រើប្រាស់វិធានផ្ទៃក្នុង ៦៦ *ស្ទួន* ប្រសិនបើកិច្ចខិតខំប្រឹងប្រែងស៊ើបសួរបែបនេះទទួលបានលទ្ធផល[21]។ ហេតុនេះ ផ្អែកតាម ស្ថានភាពស៊ើបសួរបច្ចុប្បន្ននេះ កិច្ចស៊ើបសួរស្វែងរកទីតាំងគុក ៨១០ នឹងត្រូវផ្អាក ហើយកិច្ច ខិតខំប្រឹងប្រែងស៊ើបសួរស្វែងរកទីតាំងនេះនឹងត្រូវកម្រិតនៅត្រឹមអង្គហេតុដែលបានស៊ើបសួរ នៅកន្លែងដែលប្រហែលជាទីតាំងគុកនោះ។

១៩. ចំពោះអង្គហេតុទី ៥ ស.ព.អ មិនប្រមើលឃើញថាមានការជំទាស់ណាមួយប្រឆាំងនឹង ចំណុចដែលថាមិនបានរកឃើញមន្ទីរសន្តិសុខផ្សេងទៀតរបស់ ក.ប.ក ឡើយ ហើយក៏នឹងមិន ជំទាស់មិនឱ្យប្រើប្រាស់វិធានផ្ទៃក្នុង ៦៦ *ស្ទួន* ដែរ ប្រសិនបើផ្អាកកិច្ចស៊ើបសួរ ហើយរក ឃើញមន្ទីរសន្តិសុខបែបនេះនៅក្នុងកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ[22]។

iv. **អង្គហេតុប្រភេទ គ៖ អង្គហេតុទី ៨**

២០. នៅក្នុងកិច្ចស៊ើបសួរដំណាក់កាលបច្ចុប្បន្ននេះ ខ្ញុំកត់សម្គាល់លើទឡ្ហីករណ៍របស់ ស.ព.អ អំពី អង្គហេតុទី ៨[23] ប៉ុន្តែ កិច្ចស៊ើបសួរលើកងពល ៥០២ និង ៣១០ បានឈានចូលដល់ដំណាក់ កាលកម្រិតខ្ពស់ណាស់ទៅហើយ ហើយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មស្ថិតនៅក្រោមកិច្ចស៊ើបសួរ

[20]ចម្លើយតប កថាខណ្ឌ ១៧។

[21]ចម្លើយតប កថាខណ្ឌ ១៦។

[22]ចម្លើយតប កថាខណ្ឌ ១៨។

[23]ចម្លើយតប កថាខណ្ឌ ២២។

ដែលកំពុងដំណើរការយ៉ាងសកម្ម។ ជាងនេះទៀត ខ្ញុំមិនយល់ឃើញថា ការមិនបន្តកិច្ចស៊ើបសួរនេះនឹងទទួលបានប្រយោជន៍សម្រាប់ល្បឿននៃកិច្ចស៊ើបសួរឡើយ។ ហេតុនេះ ខ្ញុំមានបំណងបន្តកិច្ចស៊ើបសួរនេះ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

២១. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតទេលើអង្គហេតុទី ១ ដល់ ទី ៧ ប៉ុន្តែ នឹងបន្តស៊ើបអង្កេតលើអង្គហេតុទី ៨។

២២. **ជូនដំណឹង** ភាគីទាំងអស់ថា ដីកាសម្រេចលើការលើកលែងការចោទប្រកាន់មួយចំនួនយោងតាមវិធានផ្ទៃក្នុង ៦៧ ឬការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* នឹងត្រូវធ្វើឡើងនៅពេលបញ្ចប់កិច្ចស៊ើបសួរ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**